## ក្រសួងមុខងារសាធារណៈ

## គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៦
# ស្តីពី
# ការអនុវត្តកម្មវិធីជាតិកំណែទម្រង់
# រដ្ឋបាលសាធារណៈ ២០១៥-២០១៨

លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ខែធ្នូ ឆ្នាំ២០១៦

# មាតិកា


១. សេចក្តីផ្តើម......១
២. វឌ្ឍនភាពការងារ......១
២.១ ការកែលម្អគុណភាពសេវាសាធារណៈ......២
២.២ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស......១១
២.៣ ការកែទម្រង់ប្រព័ន្ធបៀវត្ស......២៣
៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ......២៩
៤. ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ......៣៣
៥. បញ្ហាប្រឈម......៣៤
៦. វិធានការដោះស្រាយ......៣៥
៧. មេរៀនទទួលបានក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីជាតិ......៣៥
៨. ទិសដៅការងារអាទិភាពជំហានបន្ទាប់......៣៦
៨.១.ការកែលម្អគុណភាពសេវាសាធារណៈ......៣៦
៨.២.ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស......៣៧
៨.៣.ការកែទម្រង់ប្រព័ន្ធបៀវត្ស......៣៧
៨.៤.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ......៣៨
៩. សន្និដ្ឋាន......៣៨

## ១. សេចក្តីផ្តើម

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ បានអនុវត្តចាប់តាំងពីឆ្នាំ ២០១៥ ទទួលបានលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ធៀបទៅនឹងផែនការសកម្មភាពដែលបានដាក់ចេញ។ នៅក្នុងកម្មវិធីជាតិបានកំណត់ផែនការសកម្មភាពសម្រាប់អនុវត្តជាជំហាន ក្នុងនោះផ្តោតលើ៖ ការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស។

នៅក្នុងឆ្នាំ២០១៦ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈត្រូវអនុវត្តតាមតួនាទីភារកិច្ចនិងផែនការសកម្មភាពដែលបានកំណត់នៅក្នុងកម្មវិធីជាតិ និងត្រូវធ្វើការតាមដានត្រួតពិនិត្យជាប្រចាំ ដើម្បីពិនិត្យលើលទ្ធផលការងារជាដំណាក់កាលៗ ថាតើសម្រេចបានកម្រិតណា។ ទន្ទឹមនឹងនេះ ផែនការសកម្មភាពដែលត្រូវអនុវត្ត រួមមាន៖ (១)ការកែលម្អគុណភាពសេវាសាធារណៈ (២)ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស (៣)ការកែទម្រង់ប្រព័ន្ធបៀវត្ស (៤)ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង (៥)ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ។

ក្នុងឆ្នាំ២០១៦ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ សម្រេចបានលទ្ធផលមួយចំនួនដូចមានបង្ហាញជូនក្នុងតារាងវឌ្ឍនភាពការងារដូចខាងក្រោម។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការតាមដានត្រួតពិនិត្យមើលទៅលើវឌ្ឍនភាពការងារ គឺតម្រូវឱ្យមានការកំណត់ជាសញ្ញាសម្គាល់ថាតើសកម្មភាពណាមួយសម្រេចបានពេញលេញ សម្រេចបានដោយផ្នែក និងសកម្មភាពដែលមិនបានអនុវត្ត។ សញ្ញាសម្គាល់នេះនឹងបង្ហាញដូចខាងក្រោម៖

| ការកំណត់អត្ថន័យ | សញ្ញាសម្គាល់ |
|---|---|
| សកម្មភាពដែលសម្រេចបានពេញលេញ | √ |
| សកម្មភាពដែលសម្រេចបានដោយផ្នែក | Ø |
| សកម្មភាពដែលមិនទាន់បានអនុវត្ត | X |

## ២ .វឌ្ឍនភាពការងារ

ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ក្នុងឆ្នាំ២០១៦ ដោយផ្តោតទៅលើការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស មានវឌ្ឍនភាពការងារជាវិជ្ជមានមួយចំនួនគួរឱ្យកត់សម្គាល់ ក្នុងនោះមានដូចជា៖

| សកម្មភាពការងារ | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | |
|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បាន អនុវត្ត |
| **ការកែលម្អគុណភាពសេវាសាធារណៈ** | ១៣ | ១ | ១២ | ០ |
| **ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស** | ១៦ | ០ | ១៤ | ២ |
| **ការកែទម្រង់ប្រព័ន្ធបៀវត្ស** | ៦ | ៤ | ២ | ០ |
| សរុប | ៣៥ | ៥ | ២៨ | ២ |

## ២.១. ការកែលម្អគុណភាពសេវាសាធារណៈ

នៅក្នុងការកែលម្អគុណភាពសេវាសាធារណៈដែលបានកំណត់ផែនការសកម្មភាពនៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ បានដាក់ចេញចង្កោមសកម្មភាពចំនួន ០៧ ដោយឡែកចង្កោមសកម្មភាពទី៤ បានអនុវត្តរួចរាល់នៅក្នុងឆ្នាំ២០១៥ រួចមកហើយ។ នៅក្នុងឆ្នាំ២០១៦នេះ ចង្កោមសកម្មភាពដែលត្រូវអនុវត្ត គឺមានចំនួន **០៦ ចង្កោមសកម្មភាព** ក្នុងនោះមាន**ផែនការសកម្មភាពលម្អិតចំនួន ១៣** ដូចជា៖

| ចង្កោមសកម្មភាព | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | |
|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
| ចង្កោមសកម្មភាពទី១ | ៣ | ០ | ៣ | ០ |
| ចង្កោមសកម្មភាពទី២ | ១ | ០ | ១ | ០ |
| ចង្កោមសកម្មភាពទី៣ | ២ | ០ | ២ | ០ |
| *ចង្កោមសកម្មភាពទី៤* | *បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ* | | | |
| ចង្កោមសកម្មភាពទី៥ | ២ | ០ | ២ | ០ |
| ចង្កោមសកម្មភាពទី៦ | ២ | ០ | ២ | ០ |
| ចង្កោមសកម្មភាពទី៧ | ៣ | ១ | ២ | ០ |
| សរុប | ១៣ | ១ | ១២ | ០ |



រូបភាព៖ពិធីប្រកាសដាក់ឲ្យដំណើរការនិងផ្សព្វផ្សាយជាផ្លូវការកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមរយៈទូរស័ព្ទស្មាតហ្វូនថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល



ការកែលម្អគុណភាពសេវាសាធារណៈ មានសកម្មភាពដែលត្រូវអនុវត្តចំនួន១៣ ដែលក្នុងនោះសកម្មភាពដែលសម្រេចបានពេញលេញមានចំនួន០១ និងសកម្មភាពដែលសម្រេចបានដោយផ្នែកមានចំនួន១២។

**ក/.សកម្មភាពដែលសម្រេចបានពេញលេញ** គឺការរៀបចំបង្កើតមូលដ្ឋានទិន្នន័យជាតិគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីសាធារណៈទទួលប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភពីថវិកាជាតិ។

**ខ/.សកម្មភាពដែលសម្រេចបានដោយផ្នែក** រួមមាន៖

(១) ការរៀបចំបង្កើតនិងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា

(២) ការរៀបចំបង្កើតនិងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់ក្រសួងសុខាភិបាល

(៣) ការរៀបចំបង្កើតនិងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងយុត្តិធម៌

(៤) ការធ្វើបច្ចុប្បន្នកម្មកម្រងសេវាសាធារណៈ

(៥) ការធ្វើការសិក្សានិងចងក្រងលំហូរការងារនៃសេវាសាធារណៈសំខាន់ដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណសាងសង់ ការចុះបញ្ជីយានយន្ត ការផ្តល់បណ្ណបើកបរ ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីដីធ្លី ការផ្តល់សំបុត្រអត្រានុកូលដ្ឋាន អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែន

(៦) ការធ្វើការតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការកែលម្អសេវាសាធារណៈ

(៧) ការរៀបចំបង្កើតមជ្ឈមណ្ឌលទូរស័ព្ទ (Call Centre)

(៨) ការតាមដានត្រួតពិនិត្យការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងច្រកចេញចូលតែមួយ

(៩) ការរៀបចំដាក់ឲ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវានៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

(១០)ការរៀបចំបង្កើតមជ្ឈមណ្ឌលជាតិទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

(១១)ការរៀបចំច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មាន (Public Service Gateway)

(១២)ការរៀបចំនិងដាក់ឲ្យអនុវត្តការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យាដោយមានការផ្សារភ្ជាប់គ្នាជាប្រព័ន្ធក្នុងរដ្ឋបាលសាធារណៈ។

ខាងក្រោមនេះ គឺជាតារាងវឌ្ឍនភាពការងារធៀបទៅនឹងផែនការសកម្មភាពដែលបានដាក់ចេញ៖

| **ចង្កោមសកម្មភាព១.១៖ រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ** | **វឌ្ឍនភាពការងារ** | **សកម្មភាពដែលសម្រេចបានពេញលេញ** | **សកម្មភាពដែលសម្រេចបានដោយផ្នែក** | **សកម្មភាពដែលមិនទាន់បានអនុវត្ត** |
|---|---|---|---|---|
| ១.១.១ ការរៀបចំបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង អប់រំ យុវជន និងកីឡា | - លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រុមការងារនៃក្រសួងមុខងារសាធារណៈបាននិងកំពុងរៀបចំសិក្សាស្រាវជ្រាវ ប្រមូលឯកសារជាតុចូលមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយនៅក្នុងនោះបានសិក្សានិងប្រមូលឯកសារពីក្រសួងទេសចរណ៍ ក្រសួងមហាផ្ទៃការិយាល័យច្រកចេញចូលតែមួយ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងប្រទេសឥណ្ឌូនេស៊ី ដោយក្នុងនោះពិនិត្យមើលលើសូចនាករសំខាន់ៗមួយចំនួនដែលបានអនុវត្ត។ | | Ø | |
| ១.១.២ ការរៀបចំបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងសុខាភិបាល | | | Ø | |
| ១.១.៣ ការរៀបចំបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងយុត្តិធម៌ | | | Ø | |

**ទិសដៅអនុវត្តបន្ត**

១. បន្តរៀបចំបញ្ចប់ការបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងមហាផ្ទៃ(ច្រកចេញចូលតែមួយ) និងក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងសុខាភិបាល

២. រៀបចំបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃគុណផលរបស់អង្គភាពផ្តល់សេវាសាធារណៈ

| ចង្កោមសកម្មភាព១.២៖ ធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈ ព្រមទាំងជំរុញការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសេវាសាធារណៈជាពិសេសតាមប្រព័ន្ធអេឡិចត្រូនិច | វឌ្ឍនភាពការងារ | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ១.២.១.ធ្វើបច្ចុប្បន្នកម្មកម្រងសេវាសាធារណៈ | - លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានអនុវត្តការងារក្នុងការធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈ ជាលទ្ធផលមានក្រសួងស្ថាប័នអង្គភាពផ្តល់សេវាចំនួន ២៦ បានផ្ញើកម្រងព័ត៌មានសេវាសាធារណៈដែលបាននិងកំពុងធ្វើបច្ចុប្បន្នកម្មមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។ ឯកសារដែលបានធ្វើសុក្រឹត្យភាពរួចរាល់ក្រុមការងារបានដាក់បញ្ចូលក្នុងគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ។ | | Ø | |

**ទិសដៅអនុវត្តបន្ត**

១. បន្តធ្វើបច្ចុប្បន្នកម្ម និងបញ្ចប់កម្រងព័ត៌មានសេវាសាធារណៈ របស់ក្រសួងមួយចំនួនដែលនៅសេសសល់

| ចង្កោមសកម្មភាព១.៣៖ កែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗដែលពាក់ព័ន្ធផ្ទាល់នឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ | វឌ្ឍនភាពការងារ | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ១.៣.១ ធ្វើការសិក្សានិងចងក្រងលំហូរការងារនៃសេវាសាធារណៈសំខាន់ដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណសាងសង់ ការចុះបញ្ជីយានយន្ត ការផ្តល់បណ្ណបើកបរ ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីដីធ្លី ការផ្តល់សំបុត្រអត្រានុកូលដ្ឋាន អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែន | - បានចុះត្រួតពិនិត្យនិងផ្តល់អនុសាសន៍កែលម្អលើសេវាអាទិភាពរបស់ក្រសួង ស្ថាប័ន ចំនួន ០៣ ដោយយកំណត់សូចនាករចំនួន ០៩ រួមមាន៖ សូចនាករទី១. បទដ្ឋានគតិយុត្ត ទី២. ការផ្សព្វផ្សាយព័ត៌មាន ទី៣. ទីតាំងនិងហេដ្ឋារចនាសម្ព័ន្ធអង្គភាពផ្តល់សេវា ទី៤. ឥរិយាបថរបស់អ្នកផ្តល់សេវា ទី៥. លក្ខខណ្ឌក្នុងការទទួលយកសេវា ទី៦. នីតិវិធីនៃការផ្តល់សេវា ទី៧. រយៈពេលនៃការផ្តល់សេវា ទី៨. តម្លៃនៃការផ្តល់សេវា ទី៩. យន្តការនៃការផ្តល់ព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា។ | | Ø | |
| ១.៣.២ ធ្វើការតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការកែលម្អសេវាសាធារណៈ | - (១) បានពិនិត្យនិងផ្តល់អនុសាសន៍លើការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តក្រចេះ សៀមរាប និង | | Ø | |

| | | | | |
|---|---|---|---|---|
| | ខេត្តកំពត ដោយផ្តោតលើសេវាសុរិយោដី និងសេវាសំណង់<br>- (២) បានផ្តល់អនុសាសន៍កែលម្អលើសេវាក្រសួងយុត្តិធម៌ ពាក់ព័ន្ធសេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស<br>- (៣) បានផ្តល់អនុសាសន៍កែលម្អលើសេវាក្រសួងពាណិជ្ជកម្មខេត្តបាត់ដំបង | | | |
| **ទិសដៅអនុវត្តបន្ត**<br>១. បន្តចុះត្រួតពិនិត្យ និងកែលម្អនីតិវិធីនិងយន្តការក្នុងការផ្តល់សេវាសាធារណៈសេវាអាទិភាពរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សុខាភិបាល រ៉ែនិងថាមពល ឧស្សាហកម្មនិងសិប្បកម្ម | | | | |
| **ចង្កោមសកម្មភាព១.៥៖ កែលម្អនីតិវិធីនិងយន្តការក្នុងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ច តាមរយៈយន្តការផ្សេងៗដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេស ច្រកចេញចូលតែមួយ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ** | **វឌ្ឍនភាពការងារ** | **សកម្មភាពដែលសម្រេចបានពេញលេញ** | **សកម្មភាពដែលសម្រេចបានដោយផ្នែក** | **សកម្មភាពដែលមិនទាន់បានអនុវត្ត** |
| ១.៥.១ រៀបចំបង្កើតមជ្ឈមណ្ឌលទូរស័ព្ទ (Call Centre) | - បានសិក្សាពីទស្សនទាននៃការដាក់ឱ្យអនុវត្តនូវមជ្ឈមណ្ឌលទូរស័ព្ទព័ត៌មានសេវាសាធារណៈ (Call Centre) ពីបណ្តាប្រទេសក្នុងតំបន់ ក្នុងនោះរួមមាន៖ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃឡង់ | | Ø | |
| ១.៥.២ តាមដានត្រួតពិនិត្យការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងច្រកចេញចូលតែមួយ | - បានចុះសិក្សាត្រួតពិនិត្យ និងពង្រីកការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស ចំនួន ០៤ បន្ថែមទៀតនៅមន្ទីរពេទ្យបង្អែក ខេត្តព្រៃវែង ខេត្តកំពត ខេត្តក្រចេះ និងខេត្តកំពង់ធំ<br>- បានរៀបចំតាក់តែងសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តយន្តការច្រកចេញចូលតែមួយដើម្បីដាក់ឱ្យអនុវត្តនៅក្រសួងមុខងារសាធារណៈ ដោយបានប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងប្រកាសកម្រិតផ្ទៃក្នុងក្រសួងចំនួន០៤ លើក និងកំណត់បញ្ជីឈ្មោះប្រភេទសេវាៗ ទន្ទឹមនឹងនេះសេចក្តីព្រាងប្រកាសនេះ ក៏បានដាក់ប្រជុំឆ្លងកម្រិតថ្នាក់ដឹកនាំដើម្បីពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងស្តីពីការផ្តល់សេវាសាធារណៈ តាមការិយាល័យច្រកចេញចូល | | Ø | |

| | | | | |
|---|---|---|---|---|
| | តែមួយរបស់ក្រសួងមុខងារសាធារណៈ<br>- បានរៀបចំដាក់ចេញសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់សេវាសាធារណៈ ដោយបានប្រជុំពិភាក្សានិងពិគ្រោះយោបល់កម្រិតបច្ចេកទេសនៃលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។ សេចក្តីព្រាងព្រះរាជក្រឹត្យនេះមានគោលដៅកំណត់ពីគោលការណ៍ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈ យន្តការនៃការផ្តល់សេវាសាធារណៈ រចនាសម្ព័ន្ធអង្គភាពផ្តល់សេវាសាធារណៈ ធនធានរបស់អង្គភាពផ្តល់សេវាសាធារណៈ សិទ្ធិ កាតព្វកិច្ច និងការហាមឃាត់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានយន្តការផ្តល់ព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា និងការអនុវត្តការផ្តល់សេវាសាធារណៈ។<br>- បានកែសម្រួលសេចក្តីព្រាងព្រះរាជក្រឹត្យទៅជាសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ<br>- បានស្រង់ទិន្នន័យនៃការអនុវត្តយន្តការផ្តល់សេវាសាធារណៈនៅតាមក្រសួង-ស្ថាប័ន៖ (១) **ទីភ្នាក់ងារប្រតិបត្តិការពិសេស** រួមមាន៖ ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (២) **ច្រកចេញចូលតែមួយ** នៅថ្នាក់ក្រោមជាតិ (ក្រុង ស្រុក ខណ្ឌ) ចំនួន ៤៦ និងថ្នាក់ជាតិរួមមាន៖ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរ៉ែនិងថាមពល ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអជ្ញាធរអប្សរា (៣) **គ្រឹះស្ថានសាធារណៈរដ្ឋបាល** រួមមាន៖ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | |

| | | | | |
|---|---|---|---|---|
| | ក្រសួងទេសចរណ៍ និងទីស្តីការគណៈរដ្ឋមន្ត្រី (៤) **សហគ្រាសសាធារណៈ** រួមមាន៖ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | | | |

**ទិសដៅអនុវត្តបន្ត**

១. រៀបចំបង្កើតមជ្ឈមណ្ឌលទូរស័ព្ទព័ត៌មានសេវាសាធារណៈ (Call Centre)

២. បន្តចុះត្រួតពិនិត្យការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមបណ្តារាជធានី ខេត្ត

៣. រៀបចំសេចក្តីព្រាងច្បាប់សេវាសាធារណៈ

| **ចង្កោមសកម្មភាព១.៦៖ រៀបចំដាក់ឱ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា** | **វឌ្ឍនភាពការងារ** | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ១.៦.១ រៀបចំដាក់ឱ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវានៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | - ក្រសួង ស្ថាប័នចំនួន ២០ ដែលមានយន្តការនៃ ការផ្តល់ព័ត៌មានត្រឡប់និងបណ្តឹងតវ៉ាក្នុងនោះ រួមមាន៖<br>- (១) **ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់** មធ្យោបាយប្រើប្រាស់រួមមាន៖ ប្រអប់សំបុត្រ ទូរស័ព្ទ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម<br>- (២) **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** មធ្យោបាយប្រើប្រាស់ រួមមាន៖ អ៊ីម៉ែល ទូរស័ព្ទ បណ្តាញទំនាក់ទំនងសង្គម<br>- (៣) **ក្រសួងពាណិជ្ជកម្ម** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ Hotline គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម<br>- (៤) **ក្រសួងសាធារណៈការនិងដឹកជញ្ជូន** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ Hotline គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម<br>- (៥) **ក្រសួងបរិស្ថាន** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ Hotline គេហទំព័រ<br>- (៦) **ក្រសួងធនធានទឹក និងឧតុនិយម** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ | | Ø | |

| | | | | |
|---|---|---|---|---|
| | អ៊ីម៉ែល ទូរស័ព្ទ Hotline គេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម<br>- (៧) **ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា** មធ្យោបាយប្រើប្រាស់ រួមមាន៖ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ<br>- (៨) **ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ<br>- (៩) **ក្រសួងយុត្តិធម៌** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម<br>- (១០) **អាជ្ញាធរអប្សរា** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល គេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម<br>- (១១) **ក្រសួងអប់រំ យុវជន និងកីឡា** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ ទូរស័ព្ទ Hotline បណ្ដាញទំនាក់ទំនងសង្គម<br>- (១២) **រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ ទូរស័ព្ទ គេហទំព័រ<br>- (១៣) **ក្រសួងព័ត៌មាន** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ<br>- (១៤) **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ<br>- (១៥) **ក្រសួងការពារជាតិ** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ ទូរស័ព្ទ មកជួបទំនាក់ទំនងដោយផ្ទាល់<br>- (១៦) **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម<br>- (១៧) **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម<br>- (១៨) **ក្រសួងរ៉ែ និងថាមពល** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ មកជួបទំនាក់ទំនងដោយផ្ទាល់ | | | |

| | | | | |
|---|---|---|---|---|
| | - (១៩) **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល ទូរស័ព្ទ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម<br>- (២០) **ក្រសួងសុខាភិបាល** មធ្យោបាយប្រើប្រាស់ រួមមាន៖ ប្រអប់សំបុត្រ អ៊ីម៉ែល គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម ទូរស័ព្ទ មកជួបទំនាក់ទំនងដោយផ្ទាល់ | | | |

**ទិសដៅអនុវត្តបន្ត**

១. ជំរុញ និងរៀបចំដាក់ឱ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

| **ចង្កោមសកម្មភាព១.៧៖ សិក្សា និងជំរុញការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា** | **វឌ្ឍនភាពការងារ** | **សកម្មភាពដែលសម្រេចបានពេញលេញ** | **សកម្មភាពដែលសម្រេចបានដោយផ្នែក** | **សកម្មភាពដែលមិនទាន់បានអនុវត្ត** |
|---|---|---|---|---|
| ១.៧.១ ការរៀបចំច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មាន(Public Service Gateway) | - បានសិក្សាលើទីតាំង ឧបករណ៍សម្ភារៈ សម្រាប់រៀបចំបង្កើតច្រកអេឡិចត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ(Public Service Gateway) ដោយបានពិគ្រោះយោបល់ប្រជុំកម្រិតបច្ចេកទេសលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | | Ø | |
| ១.៧.២ រៀបចំបង្កើតមូលដ្ឋានទិន្នន័យជាតិគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីសាធារណៈទទួលប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភពីថវិកាជាតិ | - បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីសាធារណៈ ទទួលប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភពីថវិកាជាតិ តាមប្រព័ន្ធព័ត៌មានវិទ្យាពេញលេញ | √ | | |
| ១.៧.៣ រៀបចំនិងដាក់ឱ្យអនុវត្តការផ្តល់សេវាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា ដោយមានការផ្សារភ្ជាប់គ្នាជាប្រព័ន្ធក្នុងរដ្ឋបាលសាធារណៈ | - មានក្រសួងស្ថាប័នចំនួន ០៩ ដែលបានផ្តល់សេវាតាម online ក្នុងនោះរួមមាន៖ (១) ក្រសួងពាណិជ្ជកម្ម (២)ក្រសួងទេសចរណ៍ (៣)ក្រសួងផែនការ (៤)ក្រសួងអប់រំ យុវជន និងកីឡា (៥)ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (៦)ក្រសួងសាធារណៈការ និងដឹកជញ្ជូន (៧)ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ(៨)ក្រសួងសុខាភិបាល (៩)ក្រសួងយុត្តិធម៌<br>- លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការរៀបចំបង្កើត និងប្រកាសដាក់ឲ្យដំណើរការ | | Ø | |

| | | | | |
|---|---|---|---|---|
| | ការអនុវត្តកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន (Mobile App) ដោយមានសមាសភាពចូលរួមមកពីក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត ប្រធានការិយាល័យច្រកចេញចូលទាំងអស់ អង្គការតម្លាភាពកម្ពុជា JICA KOICA UNDP World Bank ADB និងGIZ ប្រមាណ ៣០០នាក់។ នៅពេលដែលការផ្តល់ព័ត៌មានអំពីសេវាសាធារណៈតាមបច្ចេកវិទ្យាទូរស័ព្ទស្មាតហ្វូន(Mobile App) ត្រូវបានដាក់ឱ្យអនុវត្តប្រជាពលរដ្ឋនឹងអាចទទួលបានព័ត៌មានអំពីសេវាសាធារណៈគ្រប់ពេលវេលា។ | | | |
| **ទិសដៅអនុវត្តបន្ត**<br>១. បន្តរៀបចំច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មាន (Public Service Gateway)<br>២. តាមដានការអនុវត្តការផ្តល់ព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន<br>៣. បន្តជំរុញការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិច | | | | |

## ២.២. ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស

### ក/ស្ថានភាពមន្ត្រីរាជការស៊ីវិលនៅក្នុងឆ្នាំ២០១៦

នៅក្នុងតារាងខាងក្រោម នឹងបង្ហាញពីស្ថានភាពចំនួនមន្ត្រីរាជការស៊ីវិលដែលបម្រើការងារនៅក្នុងវិស័យសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានកំណត់ចំនួន ភេទ និងអាយុ។

**តារាងទី១. ចំនួនមន្ត្រីរាជការស៊ីវិល**



## តារាងទី២.ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គិតជាភាគរយ




ប្រភពទិន្នន័យ៖ តារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិល ខែសីហា ឆ្នាំ២០១៦

## តារាងទី៣. ចំនួនមន្ត្រីរាជការស៊ីវិលតាមប្រភេទក្របខណ្ឌ




ប្រភពទិន្នន័យ៖ តារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិល ខែសីហា ឆ្នាំ២០១៦

## តារាងទី៤. ចំនួនមន្ត្រីរាជការស៊ីវិលតាមអាយុ




ប្រភពទិន្នន័យ៖ តារាងបុគ្គលិកបៀវត្សមន្ត្រីរាជការស៊ីវិល ខែសីហា ឆ្នាំ២០១៦

## តារាងទី៥៖ ប្រព័ន្ធចំណាត់ថ្នាក់បៀវត្សថ្មី

| ក្របខណ្ឌ | ឋានន្តរសក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| ក | ក១ | | | | | | | | | ៤៦១ | ៤៧៩ | ៤៩៦ | ៥១៣ | ៥៣១ | ៥៥០ |
| | ក២ | | | | | ៣៩៤ | ៤១០ | ៤២៦ | ៤៤៣ | | | | | | |
| | ក៣ | ៣៤៥ | ៣៥៤ | ៣៦៤ | ៣៧៩ | | | | | | | | | | |
| ខ | ខ១ | | | | | | | | | ៣៩៣ | ៤០៧ | ៤២១ | ៤៣៦ | ៤៥៣ | ៤៧០ |
| | ខ២ | | | | | ៣៤៤ | ៣៥៨ | ៣៦៩ | ៣៨០ | | | | | | |
| | ខ៣ | ៣០០ | ៣០៨ | ៣១៨ | ៣៣១ | | | | | | | | | | |
| គ | | | | | | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | | | | | | ២៦៥ | ២៧៤ | ២៨៤ | ២៩៥ | ៣០៧ | ៣២១ | ៣៣៥ | ៣៥២ | ៣៧០ | ៣៩០ |

### ខ/ការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

នៅក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ដែលបានកំណត់ផែនការសកម្មភាពនៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ បានដាក់ចេញចង្កោមសកម្មភាពចំនួន ០៨ ប៉ុន្តែចង្កោមសកម្ម

ភាពទី៤ និងទី៥ បានអនុវត្តរួចរាល់នៅក្នុងឆ្នាំ២០១៥ រួចមកហើយ។ ដោយឡែកនៅក្នុងឆ្នាំ២០១៦នេះ ចង្កោមសកម្មភាពដែលត្រូវអនុវត្ត គឺមានចំនួន **០៦ ចង្កោមសកម្មភាព** រួមមាន**ផែនការសកម្មភាពលម្អិតចំនួន១៦** ដូចជា៖

| **ចង្កោមសកម្មភាព** | **ចំនួនសកម្មភាព** | **វឌ្ឍនភាពការងារ** | | | **ផ្សេងៗ** |
|---|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត | |
| ចង្កោមសកម្មភាពទី១ | ៥ | ០ | ៣ | ២ | |
| ចង្កោមសកម្មភាពទី២ | ៤ | ០ | ៤ | ០ | សកម្មភាពទី១និងទី២បន្តពីឆ្នាំ២០១៥ |
| ចង្កោមសកម្មភាពទី៣ | ៣ | ០ | ៣ | ០ | សកម្មភាពទី១និងទី២បន្តពីឆ្នាំ២០១៥ |
| ចង្កោមសកម្មភាពទី៤ | *បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ* | | | | |
| ចង្កោមសកម្មភាពទី៥ | *បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ* | | | | |
| ចង្កោមសកម្មភាពទី៦ | ២ | ០ | ២ | ០ | |
| ចង្កោមសកម្មភាពទី៧ | ១ | ០ | ១ | ០ | |
| ចង្កោមសកម្មភាពទី៨ | ១ | ០ | ១ | ០ | |
| សរុប | ១៦ | ០ | ១៤ | ២ | |



រូបភាព៖សិក្ខាសាលាបើកវគ្គបណ្ដុះបណ្ដាលស្ដីពី"ការជំរុញកំណែទម្រង់អភិបាលកិច្ចល្អសម្រាប់មន្ត្រីរាជការជាន់ខ្ពស់" ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ



រូបភាព៖សិក្ខាសាលាពិគ្រោះយោបល់លក្ខណៈទូលាយ ស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល" នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី

ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស មានសកម្មភាពដែលត្រូវអនុវត្តមានចំនួន១៦ ដែលក្នុងនោះ សកម្មភាពដែលសម្រេចបានដោយផ្នែកមានចំនួន១៤ និងសកម្មភាពដែលមិនទាន់បានអនុវត្តមានចំនួន០២។

**ខ១/.សកម្មភាពដែលសម្រេចបានដោយផ្នែក** រួមមាន៖

(១) រៀបចំផែនការធនធានមនុស្ស ៣ឆ្នាំ និងកសាងបទដ្ឋានគតិយុត្តសម្រាប់ការបណ្តុះបណ្តាល

(២) រៀបចំកម្មវិធីបណ្តុះបណ្តាលកម្រិតជាន់ខ្ពស់រយៈពេលខ្លី

(៣) ការរៀបចំ និងផ្តល់កម្មវិធីបណ្តុះបណ្តាលដំបូងដល់មន្ត្រីក្របខណ្ឌថ្មីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

(៤) រៀបចំមន្ត្រីរាជការស៊ីវិលទៅតាមអង្គវិជ្ជាជីវៈច្បាស់លាស់ និងកំណត់មុខតំណែង

(៥) រៀបចំលក្ខន្តិកៈសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ

(៦) សិក្សាចងក្រងមុខតំណែងសំខាន់របស់មន្ត្រីរាជការស៊ីវិលក្នុងរដ្ឋបាលសាធារណៈ និងរៀបចំឯកសារណែនាំ និងគំរូព័ត៌មានស្តីពីការពិពណ៌នា មុខតំណែងចាប់ពីកម្រិតអគ្គនាយកដល់កម្រិតអនុប្រធានការិយាល័យ

(៧) ការរៀបចំចងក្រងមុខតំណែងទាំងអស់រួមជាមួយការពិពណ៌នាមុខតំណែងក្នុងក្រសួងមុខងារសាធារណៈ

(៨) រៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល

(៩) រៀបចំប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តសម្រាប់អនុវត្តចំពោះមន្ត្រីក្នុងកម្រិតគ្រប់គ្រងថ្នាក់ជាតិនិងកម្រិតគ្រប់គ្រងថ្នាក់ក្រោមជាតិ

(១០)ការរៀបចំនិងដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលនិងប្រព័ន្ធលើកទឹកចិត្តក្នុងរដ្ឋបាលសាធារណៈ

(១១)ការធ្វើការវិភាគមុខងារ និងរចនាសម្ព័ន្ធព្រមទាំងការប្រើប្រាស់ធនធានមនុស្សរបស់ក្រសួង ស្ថាប័ន

(១២)ការពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិមុខងាររចនាសម្ព័ន្ធ និងអភិក្រមការងារ

(១៣)ការអភិវឌ្ឍ និងការពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សនៅ

តាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (១៤)ការបង្កើតចំនួនស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រង។

**២៧/.សកម្មភាពការងារដែលមិនទាន់អនុវត្ត រួមមាន៖**

(១) ការរៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និង ប្រវត្តិសមត្ថភាពការងារដោយមានយន្តការគ្រប់គ្រង និងវាយតម្លៃសម្រាប់ការធ្វើផែនការអាជីពស្រប តាមសេចក្តីត្រូវការ

(២) ការសិក្សានិងរៀបចំបង្កើតវិទ្យាស្ថានរដ្ឋបាលសាធារណៈ ដើម្បីផ្តល់ការស្រាវជ្រាវផ្នែកគោលនយោបាយ សាធារណៈ និងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងមុខងារសាធារណៈ។

ខាងក្រោមនេះគឺជាតារាងវឌ្ឍនភាពការងារធៀបទៅនឹងផែនការសកម្មភាពដែលបានដាក់ចេញ៖

| **ចង្កោមសកម្មភាព២.១៖ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្តុះ បណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិលនិងកែលម្អកម្មវិធីបណ្តុះបណ្តាលនិង ការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | **វឌ្ឍនភាពការងារ** | **សកម្មភាពដែលសម្រេចបានពេញលេញ** | **សកម្មភាពដែលសម្រេច បានដោយផ្នែក** | **សកម្មភាពដែលមិនទាន់បានអនុវត្ត** |
|---|---|---|---|---|
| ២.១.១.រៀបចំផែនការធនធានមនុស្ស ៣ ឆ្នាំរំកិល និងកសាងបទដ្ឋានគតិយុត្តសម្រាប់ការបណ្តុះបណ្តាល | - បានធ្វើបច្ចុប្បន្នកម្មការកំណត់ពីតម្រូវការនៃការបណ្តុះបណ្តាល និងខ្លឹមសារនៃកម្មវិធីនៃការបណ្តុះបណ្តាលរវាងលេខាធិការដ្ឋានកែទម្រង់ទាំង៣វិស័យ (PAR. PFM. D&D)<br>- បានរៀបចំសេចក្តីព្រាងស្តីពីព្រះរាជក្រឹត្យគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋដោយបានប្រជុំកែសម្រួលកម្រិតបច្ចេកទេសរបស់ក្រសួងមុខងារសាធារណៈនិងត្រៀមដាក់ប្រជុំកម្រិតថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនិងផ្តល់យោបល់លើឯកសារព្រាងព្រះរាជក្រឹត្យ<br>- សេចក្តីព្រាងព្រះរាជក្រឹត្យនេះ មានគោលដៅកែលម្អនីតិវិធីនិងពង្រឹងការអនុវត្តពាក់ព័ន្ធទៅនឹងការធ្វើផែនការធនធានមនុស្ស ការជ្រើសរើស ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ការឡើងថ្នាក់ ឡើងឋានន្តរសក្តិ ការតែងតាំង ក្នុងមុខតំណែង ការបណ្តុះបណ្តាល និងការ អភិវឌ្ឍសមត្ថភាព ការសិក្សាបន្តក្នុងឬក្រៅប្រទេស ការគ្រប់គ្រងគុណផល និងការលើកទឹកចិត្ត ការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ឱ្យទំនេរគ្មានបៀវត្ស ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬក្រៅតំណែង ការឈប់ | | Ø | |

| | | | | |
|---|---|---|---|---|
| | សម្រាកពីការងារ ការដាក់វិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការដោះស្រាយទំនាស់ពាក់ព័ន្ធ នឹងកិច្ចការមុខងារសាធារណៈ ការចាកចេញពីមុខងារសាធារណៈ(ការបាត់បង់សម្បទាវិជ្ជាជីវៈ ការលុបឈ្មោះពីក្របខណ្ឌមរណភាព និងការចូលនិវត្តន៍)។ | | | |
| ២.១.២. រៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និងប្រវត្តិសមត្ថភាពការងារដោយមានយន្តការគ្រប់គ្រង និង វាយតម្លៃសម្រាប់ការធ្វើផែនការអាជីពស្របតាមសេចក្តីត្រូវការ | - *មិនទាន់បានចាប់ផ្តើមអនុវត្តនៅឡើយទេ* | | | X |
| ២.១.៣. រៀបចំកម្មវិធីបណ្តុះបណ្តាលកម្រិតជាន់ខ្ពស់រយៈពេលខ្លី | - បានទទួលការឯកភាពក្នុងការរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ ដោយក្នុងនោះទទួលបានការឯកភាពជាគោលការណ៍ក្នុងការរៀបចំការបណ្តុះបណ្តាលមន្ត្រីកម្រិតជាន់ខ្ពស់ កម្រិតមធ្យម និងកម្រិតក្របខណ្ឌថ្មី<br>- វគ្គបណ្តុះបណ្តាលនេះ នឹងចាប់អនុវត្តនៅក្នុងឆមាសទី២ ឆ្នាំ២០១៦ ដោយមានសិក្ខាកាមចូលរួមកម្រិតអគ្គនាយក និងអភិបាលខេត្តគ្រប់រាជធានី ខេត្ត | | Ø | |
| ២.១.៤.រៀបចំនិងផ្តល់កម្មវិធីបណ្តុះបណ្តាលដំបូងដល់មន្ត្រីក្របខណ្ឌថ្មី នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - បានរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះបណ្តាលមន្ត្រីក្របខណ្ឌថ្មីឆ្នាំ២០១៥ នៃក្រសួងមុខងារសាធារណៈ | | Ø | |
| ២.១.៥.សិក្សានិងរៀបចំបង្កើតវិទ្យាស្ថានរដ្ឋបាលសាធារណៈ ដើម្បីផ្តល់ការស្រាវជ្រាវផ្នែកគោលនយោបាយសាធារណៈ និងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងមុខងារសាធារណៈ | - មិនទាន់បានចាប់ផ្តើមអនុវត្តនៅឡើយទេ | | | X |

**ទិសដៅអនុវត្តបន្ត**

១. រៀបចំនិងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាលនិងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

២. ពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ មធ្យម និងមន្ត្រីក្របខណ្ឌថ្មី

៣. រៀបចំបញ្ចប់ព្រះរាជក្រឹត្យគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ

| ចង្កោមសកម្មភាព២.២៖ រៀបចំអង្គមន្ត្រីរាជការស៊ីវិលមុខតំណែង និងការពិព័ណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ | វឌ្ឍនភាពការងារ | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ២.២.១. រៀបចំមន្ត្រីរាជការស៊ីវិលទៅតាមអង្គវិជ្ជាជីវៈច្បាស់លាស់ និងកំណត់មុខតំណែង | - ក្រុមការងារបាន និងកំពុងធ្វើការសិក្សាស្រាវជ្រាវនិងប្រមូលចងក្រងឯកសារពាក់ព័ន្ធនានាសម្រាប់ជាធាតុចូលនៅក្នុងការរៀបចំតាក់តែងអង្គវិជ្ជាជីវៈមន្ត្រីរាជការស៊ីវិលដោយផ្តោតទៅលើអង្គមន្ត្រីរាជការស៊ីវិល ក្នុងនោះ រួមមាន៖ អង្គអប់រំ សុខាភិបាល រដ្ឋបាល បច្ចេកទេស និងការទូត | | Ø | |
| ២.២.២.រៀបចំលក្ខន្តិកៈសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ | - បានរៀបចំនិងដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០៤ ១៦/៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បី ឱ្យមន្ត្រីរាជការស៊ីវិលទទួលបាននូវចំណេះដឹងថ្មីសម្រាប់ការអនុវត្ត<br>- បានរៀបចំសារាចរណែនាំស្តីពីបែបបទនីតិវិធីអនុវត្តព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | | Ø | |
| ២.២.៣.សិក្សាចងក្រងមុខតំណែងសំខាន់របស់មន្ត្រីរាជការស៊ីវិលក្នុងរដ្ឋបាលសាធារណៈ និងរៀបចំឯកសារណែនាំនិងគំរូព័ត៌មាន ស្តីពីការពិពណ៌នាមុខតំណែង ចាប់ពីកម្រិតអគ្គនាយក ដល់កម្រិត អនុប្រធានការិយាល័យ | - បានរៀបចំតារាងគំរូស្តីពីការពិពណ៌នាមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបានដាក់ប្រជុំពិគ្រោះយោបល់កម្រិតអន្តរក្រសួងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពន្យល់ណែនាំក្នុងការបំពេញតាមតារាងគំរូ ស្តីពីការពិពណ៌នាមុខតំណែង។<br>- បានពន្យល់បន្ថែមលក្ខណៈអន្តរក្រសួងចង្អៀតចំនួន០៤ លើកដល់ ក្រសួង ស្ថាប័ន ក្នុងការរៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធក្រសួងស្ថាប័ន<br>- ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវរៀបចំការពិពណ៌នាមុខតំណែងនេះឱ្យបានរួចរាល់ក្នុងរយៈពេលយូរបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ | | Ø | |
| ២.២.៤.រៀបចំក្រងមុខតំណែងទាំងអស់រួមជាមួយការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ | - ក្រសួង-ស្ថាប័ន ចំនួន ០៩ បានធ្វើការរៀបចំការពិពណ៌នាមុខតំណែក្នុងរចនាសម្ព័ន្ធគ្រប់គ្រង របស់ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងការងារនិង | | Ø | |

| | | | | |
|---|---|---|---|---|
| | បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន ក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាណិជ្ជកម្ម<br>- បានចុះទៅពន្យល់បន្ថែមសម្រាប់ការរៀបចំចងក្រងការពិពណ៌នាមុខតំណែងក្រសួង ស្ថាប័ននៅទីស្តីការក្រសួងកិច្ចការនារី<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន សម្រាប់ក្រសួងមុខងារសាធារណៈ ដើម្បីឆ្លើយតប និងកាលកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងការរៀបចំការចងក្រងការពិពណ៌នាមុខតំណែង ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ ឲ្យទាន់ពេលវេលា និងប្រព្រឹត្តទៅ នៅសាលាភូមិន្ទរដ្ឋបាលដែលមានរយៈពេល ០២ថ្ងៃ ដែលមាន ០២វគ្គ សម្រាប់វគ្គទី១ បណ្តុះបណ្តាលចាប់ពីអគ្គនាយក ដល់អនុប្រធាននាយកដ្ឋាន និងវគ្គទី២ បណ្តុះបណ្តាលចាប់ពីនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស ប្រធាននិងអនុប្រធានមន្ទីរមុខងារសាធារណៈគ្រប់រាជធានី ខេត្ត<br>- បានពិនិត្យ និងរៀបចំការពិពណ៌នាមុខតំណែងគ្រងគ្រងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួង ដែលមានសរុប ៦៤ មុខតំណែង និងបានបញ្ជូនទៅនាយកដ្ឋានបុគ្គលិក របស់ក្រសួងមុខងារសាធារណៈ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៦ | | | |

**ទិសដៅអនុវត្តបន្ត**

១. បន្តរៀបចំអង្គមន្ត្រីរាជការស៊ីវិល និងមុខតំណែងវិជ្ជាជីវៈ

២. បញ្ចប់ការរៀបចំការពិព័ណ៌នាមុខតំណែងក្នុងមុខងារសាធារណៈក្នុងរចនាសម្ព័ន្ធគ្រប់គ្រង

| ចង្កោមសកម្មភាព២.៣៖ រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | វឌ្ឍនភាពការងារ | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ២.៣.១.រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល | - បានរៀបចំ និងដាក់ចេញនូវអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។ អនុក្រឹត្យនេះមានគោលដៅកំណត់អំពីប្រព័ន្ធគ្រប់គ្រងវត្តមានទណ្ឌកម្មខាងវិន័យចំពោះអវត្តមានគ្មានការអនុញ្ញាត និងការលើកទឹកចិត្ត ព្រមទាំងយន្តការគ្រប់គ្រង និងត្រួតពិនិត្យចំពោះមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។<br>- អនុក្រឹត្យនេះ ត្រូវរៀបចំផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងវត្តមានសម្រាប់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យានៅតាមអង្គភាពក្រោមឱវាទគ្រប់កម្រិតឱ្យបានរួចរាល់មុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៦ | | Ø | |
| ២.៣.២. ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តសម្រាប់អនុវត្តចំពោះមន្ត្រីក្នុងកម្រិតគ្រប់គ្រងថ្នាក់ជាតិ និងមន្ត្រីកម្រិតគ្រប់គ្រងថ្នាក់ក្រោមជាតិ | - បានរៀបចំសេចក្តីព្រាងឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់វិស័យមុខងារសាធារណៈ និងបានដាក់ឆ្លងកិច្ចប្រជុំកម្រិតបច្ចេកទេសរបស់ក្រសួងមុខងារសាធារណៈ និងដាក់ប្រជុំពិភាក្សា និងពិគ្រោះយោបល់កម្រិតអន្តរក្រសួងទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនិងកិច្ចប្រជុំរវាងលេខាធិការដ្ឋានកែទម្រង់ទាំង៣ (PFM, D&D, PAR) ដើម្បីពិនិត្យផ្តល់យោបល់ និងកែសម្រួលលើសេចក្តីព្រាងឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់វិស័យមុខងារសាធារណៈ<br>- សេចក្តីព្រាងឯកសារណែនាំនេះ ផ្តោតទៅលើចំនុចសំខាន់ៗមួយចំនួន រួមមាន៖ ផែនការការងារប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន ផែនការការងារប្រចាំឆ្នាំរបស់អង្គភាព ការពិពណ៌នាមុខតំណែង លក្ខខណ្ឌការងារ ការគ្រប់គ្រងវត្តមាន របាយការណ៍លទ្ធផល និងការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃគុណផលការងារ។<br>- បានពិភាក្សានិងពិគ្រោះយោបល់លើឯកសារ | | Ø | |

| | | | | |
|---|---|---|---|---|
| | ណែនាំស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល" សម្រាប់វិស័យមុខងារសាធារណៈរវាងលេខាធិការដ្ឋានកំណែទម្រង់ទាំង ០៣ នៅសាលាភូមិន្ទរដ្ឋបាល<br>- បានពិភាក្សារៀបចំពីតារាងផែនការសកម្មភាព និងបទដ្ឋានគតិយុត្តមួយចំនួន ដែលពាក់ព័ន្ធសម្រាប់គាំទ្រដល់ឯកសារណែនាំស្តីពី"ប្រព័ន្ធគ្រប់គ្រងគុណផល" កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦<br>- បានរៀបចំកម្មវិធី និងខ្លឹមសារសិក្ខាសាលាពិគ្រោះយោបល់លក្ខណៈទូលាយស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល "ដើម្បីបញ្ចប់សេចក្តីព្រាងឯកសារណែនាំ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយមុននឹងដាក់ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អនុម័តកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៦ | | | |
| ២.៣.៣.រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលនិងប្រព័ន្ធលើកទឹកចិត្តក្នុងរដ្ឋបាលសាធារណៈ | - ***រង់ចាំការរៀបចំបញ្ចប់ និងអនុម័តលើឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផល*** | | Ø | |

**ទិសដៅអនុវត្តបន្ត**

១. រៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តឯកសារគោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលការងារ

២. ចុះត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា

| **ចង្កោមសកម្មភាព២.៦៖ ធ្វើការវិភាគមុខងារ និងត្រួតពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | **វឌ្ឍនភាពការងារ** | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ២.៦.២. ធ្វើការវិភាគមុខងារ និងរចនាសម្ព័ន្ធព្រមទាំងការប្រើប្រាស់ធនធានមនុស្ស របស់ក្រសួងស្ថាប័ន | - បានរៀបចំទម្រង់បែបបទដើម្បីចុះត្រួតពិនិត្យ និងធ្វើជំរឿនការមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីឧទ្យានុរក្សដោយមានការឯកភាពរវាងក្រសួងមុខងារសាធារណៈ និងក្រសួងបរិស្ថាន សំដៅពង្រឹងការគ្រប់គ្រងមន្ត្រី និងកំណត់ពីតម្រូវការប្រើប្រាស់មន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីឧទ្យានុរក្សដែលបានបម្រើការងារជាក់ស្តែងនៅថ្នាក់ក្រសួង ថ្នាក់មន្ទីររាជធានី ខេត្តទូទាំងប្រទេស<br>- ការចុះធ្វើជំរឿននេះបានអនុវត្តលើថ្នាក់ក្រសួង និងខេត្តចំនួន ២០ រួមមាន៖ រាជធានីភ្នំពេញ | | Ø | |

| | | | | |
|---|---|---|---|---|
| | ខេត្តកណ្តាល តាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប ឧត្តរមានជ័យ កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ កែប កំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី រកឃើញករណីផ្ទេរចូល-ចេញ អវត្តមានមានមូលហេតុ (ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស និងមានជម្ងឺជាដើម) និងករណីខុសថ្ងៃខែឆ្នាំកំណើត។<br>- បានរៀបចំ និងដាក់ចេញនូវឯកសារសម្រាប់ចុះស្រង់ទិន្នន័យមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យានៃក្រសួងសុខាភិបាល | | | |
| ២.៦.៣. ពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិមុខងាររចនាសម្ព័ន្ធ និងអភិក្រមការងារ | - បានរៀបចំ និងដាក់ចេញនូវអនុក្រឹត្យលេខ ១១៤ អនក្រ.បកចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការបំពេញមុខងារ ការកំណត់គណនេយ្យភាព និងការទទួលខុសត្រូវ នៅតាមកម្រិតឋានានុក្រមនៃមុខតំណែងនីមួយៗក្នុងមុខងារសាធារណៈ<br>- បានចុះសិក្សាលើមុខងារ និងរចនាសម្ព័ន្ធ និងនីតិវិធីនៃការអនុវត្តការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ខេត្តចំនួន ០៥ រួមមាន៖ ខេត្តកំពង់ធំ ខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី។<br>- បានរៀបចំកម្មវិធីចែករំលែកចំណេះដឹង និងបទពិសោធន៍សម្រាប់មន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ កម្រិតប្រធានការិយាល័យ ចំនួន ៤៩នាក់ នៅសាលាភូមិន្ទ រដ្ឋបាល | | Ø | |

**ទិសដៅអនុវត្តបន្ត**

១.បញ្ចប់ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន និងដាក់ចេញនូវរបាយការណ៍លទ្ធផល

២. អនុវត្តការចុះត្រួតពិនិត្យ/ជំរឿនមន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល។

| ចង្កោមសកម្មភាព២.៧៖ អភិវឌ្ឍនិង ពង្រីកការ | វឌ្ឍនភាពការងារ | សកម្មភាពដែល | សកម្មភាពដែល | សកម្មភាពដែលមិន |
|---|---|---|---|---|

| ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងធនធានមនុស្សនៅ តាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ | | សម្រេចបានពេញលេញ | សម្រេចបានដោយផ្នែក | ទាន់បានអនុវត្ត |
|---|---|---|---|---|
| ២.៧.១.អភិវឌ្ឍនិងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - បានរៀបចំកែសម្រួលប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិល និងតារាងទូទាត់បៀវត្សឱ្យស្របតាមសារាចរស្តីពី ការកែសម្រួលនីតិវិធី នៃការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍<br>- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិល និងតារាងទូទាត់បៀវត្ស Drag & Drop និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងតារាងបៀវត្សសម្រាប់ការប្រើប្រាស់ មន្ត្រីជាប់កិច្ចសន្យា គ្រូជាប់កិច្ចសន្យា និងដំណើរការប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច | | ø | |

**ទិសដៅអនុវត្តបន្ត**

១.បន្តរៀបចំអភិវឌ្ឍនិងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

| ចង្កោមសកម្មភាព២.៨៖ បញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ | វឌ្ឍនភាពការងារ | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ២.៨.១.បង្កើនចំនួនស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រង | - ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីទូទាំងរាជធានី ខេត្ត នៅក្នុងមុខងារសាធារណៈមានចំនួន ៦៦ ១៨៩ រូប | | ø | |

**ទិសដៅអនុវត្តបន្ត**

១. បន្តជំរុញ និងបង្កើនចំនួនស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រង

## ២.៣. ការកែទម្រង់ប្រព័ន្ធបៀវត្ស

តារាងខាងក្រោម បង្ហាញពីស្ថានភាពបៀវត្សមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៦ និងតារាងបៀវត្សមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ ២០១៥-២០១៦ និងការព្យាករណ៍សម្រាប់ឆ្នាំ២០១៧ និង ២០១៨។

## តារាងទី៦៖ ប្រភេទក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

| ក្របខណ្ឌ គ | | | ក្របខណ្ឌ ខ | | | | | | | | | ក្របខណ្ឌ ក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឋានន្តរស័ក្តិទី៣ | | | ឋានន្តរស័ក្តិទី២ | | | ឋានន្តរស័ក្តិទី១ | | | ឋានន្តរស័ក្តិទី៣ | | | ឋានន្តរស័ក្តិទី២ | | | ឋានន្តរស័ក្តិទី១ | | |
| ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ | ថ្នាក់ | សន្ទស្សន៍ | ទឹកប្រាក់ |
| 1 | 390 | 648,000 | | | | | | | 1 | 470 | 780,000 | | | | | | | 1 | 550 | 912,000 |
| 2 | 370 | 612,000 | | | | | | | 2 | 453 | 752,000 | | | | | | | 2 | 531 | 880,000 |
| 3 | 352 | 584,000 | | | | | | | 3 | 436 | 724,000 | | | | | | | 3 | 513 | 852,000 |
| 4 | 335 | 556,000 | | | | | | | 4 | 421 | 700,000 | | | | | | | 4 | 496 | 824,000 |
| 5 | 321 | 532,000 | | | | | | | 5 | 407 | 676,000 | | | | | | | 5 | 479 | 796,000 |
| 6 | 307 | 508,000 | | | | | | | 6 | 393 | 652,000 | | | | | | | 6 | 461 | 764,000 |
| 7 | 295 | 488,000 | | | | 1 | 380 | 632,000 | | | | | | | 1 | 443 | 736,000 | | | |
| 8 | 284 | 472,000 | | | | 2 | 369 | 612,000 | | | | | | | 2 | 426 | 708,000 | | | |
| 9 | 274 | 456,000 | | | | 3 | 358 | 592,000 | | | | | | | 3 | 410 | 680,000 | | | |
| 10 | 265 | 440,000 | | | | 4 | 344 | 572,000 | | | | | | | 4 | 394 | 652,000 | | | |
| | | | 1 | 331 | 548,000 | | | | | | | 1 | 379 | 628,000 | | | | | | |
| | | | 2 | 318 | 528,000 | | | | | | | 2 | 364 | 604,000 | | | | | | |
| | | | 3 | 308 | 512,000 | | | | | | | 3 | 354 | 588,000 | | | | | | |
| | | | 4 | 300 | 496,000 | | | | | | | 4 | 345 | 572,000 | | | | | | |

ប្រភពទិន្នន័យ តារាងខ្នាតបៀវត្សមន្ត្រីរាជការស៊ីវិល ខែសីហា ឆ្នាំ២០១៦

## តារាងទី៧៖ តារាងសង្ខេបស្តីពីការដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ ២០១៥-២០១៦

| ល.រ | បរិយាយ | ការដំឡើងបៀវត្ស | | | |
|---|---|---|---|---|---|
| | | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
| ១ | វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស | 552,800 រៀល | 700,500 រៀល | 853,500 រៀល | 1,001,800 រៀល |
| ២ | វិស័យអប់រំ | 652,800 រៀល | 800,500 រៀល | 953,500 រៀល | 1,101,800 រៀល |
| ៣ | វិស័យសុខាភិបាល | 652,800 រៀល | 800,500 រៀល | 953,500 រៀល | 1,101,800 រៀល |
| ៤ | នគរបាលជាតិ | 628,270 រៀល | 784,730 រៀល | 937,730 រៀល | 1,086,030 រៀល |
| ៥ | យោធិន | 582,430 រៀល | 733,730 រៀល | 880,730 រៀល | 1,022,430 រៀល |
| ៦ | មន្ត្រីជាប់កិច្ចសន្យា | 160,000 រៀល | 400,000 រៀល | 500,000 រៀល | 600,000 រៀល |
| ៧ | ក្រុមប្រឹក្សារាជធានី ខេត្ត | 800,000 រៀល | 870,000 រៀល | 970,000 រៀល | 1,085,000 រៀល |
| ៨ | ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | 500,000 រៀល | 650,000 រៀល | 750,000 រៀល | 860,000 រៀល |
| ៩ | ក្រុមប្រឹក្សា ឃុំ សង្កាត់ | 300,000 រៀល | 480,000 រៀល | 570,000 រៀល | 700,000 រៀល |
| ១០ | មេភូមិ | 160,000 រៀល | 200,000 រៀល | 225,000 រៀល | 250,000 រៀល |
| ១១ | អនុប្រធានភូមិ | 140,000 រៀល | 160,000 រៀល | 180,000 រៀល | 200,000 រៀល |
| ១២ | សមាជិកភូមិ | 120,000 រៀល | 140,000 រៀល | 160,000 រៀល | 180,000 រៀល |

នៅក្នុងការអនុវត្តការងារកែទម្រង់ប្រព័ន្ធបៀវត្ស ដែលបានកំណត់ផែនការសកម្មភាពនៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ បានដាក់ចេញ**ចង្កោមសកម្មភាពចំនួន០៥** ប៉ុន្តែចង្កោមសកម្មភាពទី៥ បានអនុវត្តរួចរាល់នៅក្នុងឆ្នាំ២០១៥ រួចមកហើយ។ ដោយឡែកនៅក្នុងឆ្នាំ២០១៦ ចង្កោមសកម្មភាពដែលត្រូវអនុវត្តមានចំនួន០៤ ចង្កោមសកម្មភាព ក្នុងនោះមាន**ផែនការសកម្មភាពលម្អិតចំនួន០៦** ដូចជា៖

| ចង្កោមសកម្មភាព | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត | |
| ចង្កោមសកម្មភាពទី១ | ២ | ១ | ១ | ០ | |
| ចង្កោមសកម្មភាពទី២ | ២ | ២ | ០ | ០ | |
| ចង្កោមសកម្មភាពទី៣ | ១ | ០ | ១ | ០ | |
| ចង្កោមសកម្មភាពទី៤ | ១ | ១ | ០ | ០ | |
| ចង្កោមសកម្មភាពទី៥ | *បានអនុវត្តរួចរាល់នៅឆ្នាំ២០១៥* | | | | |
| **សរុប** | ៦ | ៤ | ២ | ០ | |

ការកែទម្រង់ប្រព័ន្ធបៀវត្ស មានសកម្មភាពដែលត្រូវអនុវត្តមានចំនួន០៦ ដែលក្នុងនោះសកម្មភាពដែលសម្រេចបានពេញលេញមានចំនួន០៤ និងសកម្មភាពដែលសម្រេចបានដោយផ្នែកមានចំនួន០២។

**ក/.សកម្មភាពដែលសម្រេចបានពេញលេញ** រួមមាន៖

(១) ការរៀបចំនិងដាក់ឲ្យអនុវត្តការបញ្ជូននិងទទួលទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធព័ត៌មានអេឡិចត្រូនិច រវាងក្រសួងមុខងារសាធារណៈជាមួយនឹងអគ្គនាយកដ្ឋានធនាគារជាតិ និងធនាគារដៃគូ

(២) ការរៀបចំបង្កើតកម្មវិធីនិងតារាងបៀវត្សមន្ត្រីជាប់កិច្ចសន្យានៅក្នុងប្រព័ន្ធទិន្នន័យរួមមន្ត្រីរាជការស៊ីវិល

(៣) ការរៀបចំដាក់ឲ្យអនុវត្តការបើកបៀវត្សមន្ត្រីជាប់កិច្ចសន្យាទៅតាមប្រព័ន្ធធនាគារ

(៤) ការរៀបចំកែសម្រួលប្រាក់បំណាច់មុខងាររបស់នគរបាលជាតិនិងយោធិនឲ្យមានសង្គតិភាពទៅនឹងប្រាក់បំណាច់មុខងារមន្ត្រីរាជកាស៊ីវិល។

**ខ/.សកម្មភាពដែលសម្រេចបានដោយផ្នែក** រួមមាន៖

(១) ការរៀបចំនិងដាក់ឲ្យអនុវត្តកម្មវិធីបញ្ជូននិងទទួលឯកសារបៀវត្សតាមប្រព័ន្ធអេឡិចត្រូនិច (Drag and Drop System)

(២) ការរៀបចំកំណត់ឡើងវិញនូវប្រាក់ម៉ោងបន្ថែមសម្រាប់វិស័យអប់រំ និងប្រាក់វេនយាមសម្រាប់វិស័យសុខាភិបាល។

ខាងក្រោមនេះគឺជាតារាងវឌ្ឍនភាពការងារធៀបទៅនឹងផែនការសកម្មភាពដែលបានដាក់ចេញ៖

| ចង្កោមសកម្មភាព៣.១៖ រៀបចំ និងដាក់ឱ្យអនុវត្តការបើកផ្តល់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាតាមធនាគារ ដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច | វឌ្ឍនភាព | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ៣.១.១ រៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីបញ្ជូននិងទទួលឯកសារបៀវត្សតាមប្រព័ន្ធអេឡិចត្រូនិច( Drag and Drop system ) | - បានដាក់ឱ្យអនុវត្ត នៅខេត្តមួយចំនួនក្នុងនោះរួម មានខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ជាដើម | | ∅ | |
| ៣.១.២ រៀបចំ និងដាក់ឲ្យអនុវត្តការបញ្ជូន និងទទួលទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធព័ត៌មានអេឡិចត្រូនិចរវាង ក្រសួងមុខងារសាធារណៈជាមួយនឹង អគ្គនាយកដ្ឋានរតនាគារជាតិ និងធនាគារដៃគូ | - មន្ត្រីរាជការស៊ីវិលទាំងអស់ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ ដោយផ្អែកលើកម្មវិធីផ្ទេរទិន្នន័យបៀវត្សតាមប្រព័ន្ធអេឡិចត្រូនិច | √ | | |

**ទិសដៅអនុវត្តបន្ត**

១. បន្តពង្រឹកការអនុវត្តប្រព័ន្ធបញ្ជូន និងទទួលឯកសារបៀវត្សតាមប្រព័ន្ធអេឡិចត្រូវនិចឱ្យបានទូទាំងប្រទេស

| ចង្កោមសកម្មភាព៣.២៖ រៀបចំដាក់បញ្ចូលប្រាក់បៀវត្សមន្ត្រីជាប់កិច្ចសន្យាទៅក្នុងប្រព័ន្ធទិន្នន័យរួមរបស់មន្ត្រីរាជការ និងបើកផ្តល់តាមប្រព័ន្ធធនាគារ | វឌ្ឍនភាព | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ៣.២.១ រៀបចំបង្កើតកម្មវិធី និងតារាងបៀវត្សមន្ត្រីជាប់កិច្ចសន្យានៅក្នុងប្រព័ន្ធទិន្នន័យរួមមន្ត្រីរាជការស៊ីវិល | - ក្រសួងមុខងារសាធារណៈ បានរៀបចំកម្មវិធី និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមព័ត៌មានវិទ្យា<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ២៦អនក្រ.បក ស្តីពីការកែសម្រួលនិងការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា | √ | | |
| ៣.២.៣ រៀបចំដាក់ឲ្យអនុវត្តការបើកបៀវត្សមន្ត្រីជាប់កិច្ចសន្យាទៅតាមប្រព័ន្ធធនាគារ | - មន្ត្រីជាប់កិច្ចសន្យាទាំងអស់ប្រមាណជាង ២០,០០០នាក់ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ | √ | | |

| ចង្កោមសកម្មភាព៣.៣៖ រៀបចំ និងកែសម្រួលឱ្យបានរួចរាល់ប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិលដោយផ្តោតលើការកែសម្រួលបៀវត្សមូលដ្ឋានប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ ស៊ីវិលទាំងអស់ឱ្យមានសង្គតិភាព សមធម៌និងឆ្លើយតបនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ផលិតភាព និងការផ្តល់សេវា | វឌ្ឍនភាព | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ៣.៣.២ បន្តរៀបចំកែសម្រួលប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ | - រៀបចំបង្កើតដំឡើងបៀវត្សសម្រាប់មន្ត្រីរាជការព្រមទាំងរបបសន្តិសុខសង្គម និងប្រាក់វិភាជន៍គ្រួសារសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន សម្រាប់ឆ្នាំ២០១៧<br>- បានរៀបចំសេណារីយ៉ូបៀវត្សសម្រាប់ឆ្នាំ២០១៩-២០២៣<br>- បានប្រជុំពិភាក្សាលើសំណើកំណត់គោលការផ្តល់ការលើកទឹកចិត្តដល់នាយកសាលាចំណេះដឹងទូទៅ នាយកគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូ និងគ្រូឧទ្ទេស<br>- បានដាក់ឲ្យអនុវត្តអនុក្រឹត្យស្តីពីគ្រូពុទ្ធិកៈសិក្សា និងមន្ត្រីបម្រើការងារក្នុងអគ្គាធិការដ្ឋានពុទ្ធិកៈសិក្សាជាតិ<br>- បានរៀបចំអនុក្រឹត្យស្តីពី ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ | | | |
| ៣.៣.៥ រៀបចំកំណត់ឡើងវិញនូវប្រាក់ម៉ោងបន្ថែមសម្រាប់វិស័យអប់រំនិងប្រាក់វេនយាមសម្រាប់វិស័យសុខាភិបាល | - បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកម្រិតរបបម៉ោង កំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់បុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ<br>- បានពិនិត្យ និងពិភាក្សាលើនីតិវិធីនៃការផ្តល់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ | | Ø | |

**ទិសដៅអនុវត្តបន្ត**

១.ត្រូវរៀបចំបញ្ចប់អនុក្រឹត្យស្តីពីការកម្រិតរបបម៉ោង កំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់បុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

២. សិក្សាទៅលើលទ្ធភាពនៃការដំឡើងប្រាក់វេនយាមសម្រាប់វិស័យសុខាភិបាល

៣. រៀបចំដំឡើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេសនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៤. រៀបចំប្រាក់ឧបត្ថម្ភប្រពន្ធ និងកូន សម្រាប់មន្ត្រីរាជការស៊ីវិលបំពេញភារកិច្ចនៅក្រៅប្រទេសនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

| ចង្កោមសកម្មភាព៣.៤៖ រៀបចំកែសម្រួលសន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ មុខងារកម្រិតអតិបរមានិងអប្បបរមារបស់នគរបាលជាតិនិងយោធិនឲ្យស្របជាមួយ និងមន្ត្រីរាជការស៊ីវិល | វឌ្ឍនភាព | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
|---|---|---|---|---|
| ៣.៤.២ រៀបចំកែសម្រួលប្រាក់បំណាច់មុខងារ របស់នគរបាលជាតិនិងយោធិនឲ្យមានសង្គតិភាពទៅនឹងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល | - បានដាក់ចេញនូវអនុក្រឹត្យលេខ១៩១ អនក្រ.បក ស្តីពីការកែប្រែតម្លៃឯកសារនៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ ៣៧ អនក្រ.បកស្តីពីការកែសម្រួល និងការដំឡើងប្រាក់បំណាច់មុខងារជូនយោធិននៃកងយោធពលខេមរភូមិន្ទ<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ ៣៨ អនក្រ.បកស្តីពីការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ ៥០ អនក្រ.បកស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ៣៩អនក្រ.បកស្តីពីប្រាក់បំណាច់មុខងារចៅក្រមនិងព្រះរាជអាជ្ញា<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ៤១អនក្រ.បកស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ ជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ<br>- បានដាក់ចេញនូវអនុក្រឹត្យលេខ៤០អនក្រ.បកស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រី ភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | | |

**ទិសដៅអនុវត្តបន្ត**

១. បន្តរៀបចំដំឡើងបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិន

២. ជំរុញការអនុវត្តសារាចរណែនាំស្តីពីបែបបទនីតិវិធីអនុវត្តព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

## ៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ






រូបភាព៖សិក្ខាសាលាថ្នាក់ជាតិស្តីពីការជំរុញនិងការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ

នៅក្នុងការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ដែលបានកំណត់នៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ គឺតម្រូវឱ្យមានការរៀបចំដាក់ចេញនូវយន្តការ និងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ការអនុវត្តកម្មវិធីជាតិនេះ ត្រូវធ្វើការត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំ ហើយត្រូវដាក់ចេញនូវរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំ ត្រីមាស ឆមាស ឆ្នាំ។

ក្នុងឆ្នាំ២០១៦ នេះ ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់តំបន់ ស្តីពីការជំរុញការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈទូទាំងប្រទេស សរុបចំនួន៦ លើក ក្នុងនោះរួម មាន៖ ថ្នាក់ជាតិចំនួន១ លើក និងថ្នាក់តំបន់ចំនួន៥ លើក ដែលមានសមាសភាពចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទូទាំង ២៥ រាជធានីខេត្ត ជាពិសេសក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ/ទីកន្លែង | សមាសភាពអ្នកចូលរួម | ចំនួនអ្នកចូលរួម | |
|---|---|---|---|---|
| | | | សរុបរួម | ស្ត្រី |
| ១ | សិក្ខាសាលាថ្នាក់ជាតិ<br>២១-កញ្ញា-២០១៦<br>រាជធានីភ្នំពេញ | គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ អគ្គនាយកនៃអគ្គិសនីកម្ពុជា ប្រធានមន្ទីរពេទ្យកាល់ម៉ែត ពេទ្យមិត្តភាពកម្ពុជាសូវៀត នាយកសាលាភូមិន្ទរដ្ឋបាលសកលវិទ្យាធិការ នៃសកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាធិការនៃសកលវិទ្យាល័យជាតិគ្រប់គ្រង សកលវិទ្យាធិការនៃសកលវិទ្យាល័យសុខាភិបាល សកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម) | ៣០០ | ៣៩ |
| ២ | សិក្ខាសាលាថ្នាក់តំបន់<br>០៧-តុលា-២០១៦<br>ខេត្តក្រចេះ | ខេត្តក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ (ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាល នាយកទីចាត់ការធនធានមនុស្ស មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត ប្រធានតុលាការខេត្ត ប្រធានមន្ទីរជំនាញទាំង២៣ ក្នុងខេត្ត ប្រធានសាខាគយនិងរដ្ឋាករខេត្ត ប្រធានសាខាពន្ធដារខេត្ត មន្ទីរមុខងារសាធារណៈ) | ២៨០ | ៣៩ |

| | | | | |
|---|---|---|---|---|
| ៣ | សិក្ខាសាលាថ្នាក់តំបន់ ២៦-តុលា-២០១៦ ខេត្តកំពង់ចាម | រាជធានីភ្នំពេញ ខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង និងខេត្តកណ្ដាល (ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាល នាយកទីចាត់ការធនធានមនុស្ស មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត ប្រធានតុលាការខេត្ត ប្រធានមន្ទីរជំនាញទាំង២៣ ក្នុងខេត្ត ប្រធានសាខាគយនិងរដ្ឋាករខេត្ត ប្រធានសាខាពន្ធដារខេត្ត មន្ទីរមុខងារសាធារណៈ) | ៣០០ | ៤៣ |
| ៤ | សិក្ខាសាលាថ្នាក់តំបន់ ០៧-វិច្ឆិកា-២០១៦ ខេត្តពោធិ៍សាត់ | ខេត្តពោធិ៍សាត់ ប៉ៃលិន បាត់ដំបង កំពង់ឆ្នាំង និងកំពង់ស្ពឺ(ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាល នាយកទីចាត់ការធនធានមនុស្ស មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត ប្រធានតុលាការខេត្ត ប្រធានមន្ទីរជំនាញទាំង២៣ ក្នុងខេត្ត ប្រធានសាខាគយនិងរដ្ឋាករខេត្ត ប្រធានសាខាពន្ធដារខេត្ត មន្ទីរមុខងារសាធារណៈ) | ២៧៧ | ៣៦ |
| ៥ | សិក្ខាសាលាថ្នាក់តំបន់ ២៣-វិច្ឆិកា-២០១៦ ខេត្តព្រះវិហារ | ខេត្តព្រះវិហារ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តកំពង់ធំ (ក្រុមការងារកែទម្រង់រដ្ឋបាលសាធា រណៈថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាល នាយកទីចាត់ការធនធានមនុស្ស មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត ប្រធានតុលាការខេត្ត ប្រធានមន្ទីរជំនាញទាំង២៣ ក្នុងខេត្ត ប្រធានសាខាគយនិងរដ្ឋាករខេត្ត ប្រធានសាខាពន្ធដារខេត្ត មន្ទីរមុខងារសាធារណៈ) | ២៩០ | ១៧ |
| ៦ | សិក្ខាសាលាថ្នាក់តំបន់ ០៧-ធ្នូ-២០១៦ ខេត្តកោះកុង | ខេត្តកោះកុង ព្រះសីហនុ កំពត កែប និងខេត្តតាកែវ (ក្រុមការងារកែទម្រង់រដ្ឋបាលសាធា រណៈថ្នាក់ក្រោមជាតិ អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត នាយករដ្ឋបាល នាយកទី | ២៩៩ | ៤៣ |

| | | | | |
|---|---|---|---|---|
| | | ចាត់ការធនធានមនុស្ស មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ស្នងការនគរបាលខេត្ត ប្រធានតុលាការខេត្ត ប្រធានមន្ទីរជំនាញទាំង២៣ ក្នុងខេត្ត ប្រធានសាខាគយនិងរដ្ឋាករខេត្ត ប្រធានសាខាពន្ធដារខេត្ត មន្ទីរមុខងារសាធារណៈ) | | |

ក្រៅពីសកម្មភាពលទ្ធផលខាងលើនេះ ក៏នៅមានវឌ្ឍនភាពការងារមួយចំនួនទៀតពាក់ព័ន្ធ ការងារត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ទទួលបានវឌ្ឍនភាពការងារដូចខាងក្រោម៖

- បានដាក់ចេញនូវឯកសារពាក់ព័ន្ធទៅនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលទទួលបានការអនុម័តពីគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ លើឯកសារគោលចំនួន០៣ ក្នុងនោះរួមមាន៖ (១) របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥ (២) តារាងផែនការការងារស្តីពីការកំណត់ទិសដៅការងារអាទិភាព២០១៦ (៣) ឯកសារគោលការណ៍ណែនាំស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។
- បានបណ្តុះបណ្តាលមន្ត្រីនៃក្រសួងមុខងារសាធារណៈ ដែលផ្តោតទៅលើវគ្គបណ្តុះបណ្តាលស្តីពីការជំរុញការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធាណៈ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ សមាសភាពដែលចូលរួមជាសិក្ខាកាម រួមមាន៖ អគ្គាធិការរង អធិការ អនុប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ប្រធានការិយាល័យ សរុប ៦០ រូប។
- បានចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំស្តីពីការរៀបចំពិពណ៌នាមុខតំណែងដល់ក្រសួង ស្ថាប័ន ប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់វិស័យមុខងារសារធារណៈការពិនិត្យលើរបាយការណ៍ នៃការសិក្សាលើមុខងារនិងរចនាសម្ព័ន្ធ និងនិតិវិធីបំពេញការងាររបស់អង្គភាពធនធានមនុស្សសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់សេវាសាធារណៈសេចក្តីព្រាងព្រះរាជ្យក្រឹត្យស្តីពីការគ្រប់គ្រងមុខងារ

  សាធារណៈ របស់រដ្ឋនិតិវិធីនៃការប្រលងជ្រើសរើសមន្ត្រីគម្រោង ASEAN Standard Service
- បានចូលរួមប្រជុំពិភាក្សានិងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ
- បានរៀបចំបង្កើត និងធ្វើបច្ចុប្បន្នភាពក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងនោះ៖ ថ្នាក់ជាតិបានចំនួន ២៣ ក្រសួង-ស្ថាប័ន និងថ្នាក់ក្រោមជាតិបានចំនួន២៥ រាជធានី-ខេត្ត
- បានចុះសិក្សាស្តីពីការអនុវត្តមុខងារគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាមួយក្រុមការងារនៅខេត្តកំពង់ធំ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១៦

- បានរៀបចំត្រួតពិនិត្យលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងវិស័យមុខងារសាធារណៈដើម្បីជំរុញការអនុវត្តបន្តមានជាកំណត់នៅក្នុងតារាងតាមដានការអនុវត្តការងារលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៦
- បានប្រជុំពិភាក្សា និងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងសារាចរស្តីពីការជ្រើសរើសការគ្រប់គ្រងមន្ត្រីរាជការមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៤. ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ

លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានអនុវត្តការងារដែលមានលក្ខណៈកែទម្រង់អន្តរវិស័យ ក្នុងនោះរួមមាន៖

(១) បានប្រជុំពិភាក្សាលើការងារសម្របសម្រួលរវាងកំណែទម្រង់ទាំង៣ (PAR PFM D&D) ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលផ្តោតជាសំខាន់ៗលើ៖ ក/ការដោះស្រាយបញ្ហាប្រឈម របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទាន ដោយ EU តាមរយៈ Budget Support ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់ទៀត ខ/យន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

(២) បានប្រជុំពិភាក្សារវាងលេខាធិការដ្ឋានទាំង៣ តំណាងក្រសួងមហាផ្ទៃ ក្រសួងអប់រំយុវជននិងកីឡានិងតំណាងសហគមន៍អឺរ៉ុប(EU SPACE) ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ នៅសណ្ឋាគារ Asia Tune ដោយផ្តោតជាសំខាន់ទៅលើ៖ ក/ពិនិត្យមើលឡើងវិញនូវសមិទ្ធផល និងសកម្មភាពអន្តរវិស័យដែលពុំទាន់សម្រេចបានក្នុងឆ្នាំ ២០១៥ និង ខ/ពិភាក្សានិងកំណត់ការងារអាទិភាពនៃផែនការការងារនិងថវិកាប្រចាំឆ្នាំ២០១៦ ។

(៣) បានរៀបចំសារាចរណែនាំស្តីពីបែបបទនីតិវិធីអនុវត្តព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

(៤) បានប្រជុំពិភាក្សារវាងកំណែទម្រង់ទាំង៣ ពាក់ព័ន្ធទៅនឹងកម្មវិធីបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ និងសិក្ខាសាលាបើកវគ្គបណ្តុះបណ្តាលនេះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល។

(៥) បានប្រជុំពិភាក្សារវាងកំណែទម្រង់ទាំង៣ ដើម្បីពិភាក្សាលើឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផល ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល។

(៦) បានប្រជុំពិភាក្សាលើការងារត្រួតគ្នា (Cross-Cutting Issues) រវាងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ កាលពីថ្ងៃទី១០ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(៧) ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋានកែទម្រង់ទាំង៣ លេខាធិការដ្ឋានទាំង៣ បានឯកភាពគ្នាបង្កើតនូវផែនការសកម្មភាពដែលត្រូវអនុវត្តរួមគ្នាដែលមានដូចខាងក្រោម៖

- ពង្រឹងការបើកផ្តល់បៀវត្សនិងប្រាក់លាភការផ្សេងៗ តាមប្រព័ន្ធធនាគារ ឬតាម E-Transfer លេខាធិការដ្ឋាន គ ក វ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត
- រៀបចំក្របខ័ណ្ឌនិងយន្តការអនុវត្តទណ្ឌកម្មចំពោះការគ្រប់គ្រងធនធានសាធារណៈ(ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត)
- កែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ឲ្យមានសមានគតិភាពជាមួយនឹងប្រព័ន្ធដំណើរការការងារថ្មីដែលរួមមាន ផ្នែករដ្ឋបាលបុគ្គលិកហិរញ្ញវត្ថុនិងផ្នែកបច្ចេកទេសទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋាន អ គ ហ ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ ក វ និង លេខាធិការដ្ឋាន គ ជ អ ប ទទួលបន្ទុកផ្នែករដ្ឋបាល បុគ្គលិក និងបច្ចេកទេស
- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធអធិការកិច្ចសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីធានាបាននូវសុខដុមនីយកម្មក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត
- បង្កើនគុណភាពលើការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសាលាភូមិន្ទរដ្ឋបាល ជាអ្នកដឹកនាំសម្របសម្រួលអនុវត្ត
- រៀបចំក្របខណ្ឌរួមនៃការគ្រប់គ្រង និងការបែងចែកប្រាក់រង្វាន់ពីចំណូលមិនមែនសារពើពន្ធ ប្រកបដោយសមធម៌ និងប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( អ.គ.ហ. ជាអ្នកដឹកនាំសម្របសម្រួលអនុវត្ត)

ទន្ទឹមនឹងនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នឹងបន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នានា ដើម្បីរៀបចំនិងអនុវត្តផែនការសកម្មភាពរួមរវាងលេខាធិការដ្ឋានកំណែទម្រង់ទាំង៣ (PAR PFM D&D)។

## ៥. បញ្ហាប្រឈម

ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនាពេលកន្លងមក ទោះបីជាទទួលបានលទ្ធផលជាវិជ្ជមានជាច្រើនយ៉ាងណាក៏ដោយក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវតែយកចិត្តទុកដាក់ក្នុងនោះរួមមាន៖

- កម្រិតការងារអាទិភាពមានច្រើននៅក្នុងការអនុវត្តដែលពិបាកនឹងសម្រេចបានតាមការគ្រោងទុក
- កម្លាំងធនធានមនុស្សមិនបានប្រមូលផ្តុំ គឺស្ថិតនៅរាយប៉ាយដែលធ្វើឱ្យផលិតភាព ប្រសិទ្ធភាព នៃការអនុវត្តការងារនៅមានកម្រិត
- ថវិកាសម្រាប់គាំទ្រដល់ដំណើរការអនុវត្តកម្មវិធីជាតិនៅមានការយឺតយ៉ាវ នីតិវិធីច្រើន ស្មុគស្មាញ ដែលធ្វើឱ្យការទម្លាក់និងផ្តល់ថវិកាសម្រាប់ការអនុវត្តមិនបានទាន់ពេលវេលា
- ខ្វះការគាំទ្រពីដៃគូអភិវឌ្ឍន៍ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការងារមួយចំនួន
- សមត្ថភាព និងចំណេះដឹងរបស់មន្ត្រីរាជការនៅក្នុងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីទស្សនទាន និងការចូលរួមអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត
- មន្ត្រីរាជការសាធារណៈ ឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់នៅក្នុងការងារកែទម្រង់នៅមានកម្រិត
- វិន័យនៅក្នុងការបំពេញការងាររបស់មន្ត្រីរាជការសាធារណៈ នៅមានកម្រិត
- សមត្ថភាពក្នុងការគ្រប់គ្រងការងារមិនបានក្លាយជាប្រព័ន្ធការងារ (យន្តការនៃការគ្រប់គ្រង)
- ការលើកទឹកចិត្ត ទាំងថវិកា និងមិនមែនថវិកា នៅតែជាបញ្ហាសម្រាប់អ្នកអនុវត្តការងារកែទម្រង់
- យន្តការ និងប្រព័ន្ធរាយការណ៍នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅមានកម្រិត។

## ៦. វិធានការដោះស្រាយ

ទន្ទឹមនឹងការជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដូចដែលបានរៀបរាប់ពីខាងលើ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក៏បានឯកភាពដាក់ចេញនូវដំណោះស្រាយសមស្របមួយចំនួនដូចខាងក្រោម៖

(១) ដំណោះស្រាយដាក់លាក់ក្នុងការអនុវត្តផែនការសកម្មភាព ក្នុងត្រូវផ្តោតទៅលើចំណុចដូចខាងក្រោម៖
- គួរធ្វើអាទិភាវូបនីយកម្មលើការងារអាទិភាព
- ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានផែនការសកម្មភាពជាក់លាក់ក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ក្រសួងមុខងារសាធារណៈ ជាអ្នកផ្តល់ការគាំទ្រផ្នែកប្រឹក្សាយោបល់ និងការបណ្តុះបណ្តាល
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវចូលរួមអនុវត្តការងារកែទម្រង់ឱ្យបានសកម្ម
- ត្រូវមានប្រព័ន្ធវាយតម្លៃលើការបណ្តុះបណ្តាលសមត្ថភាព

(២) ដំណោះស្រាយការងារសម្របសម្រួល ក្នុងត្រូវផ្តោតទៅលើ៖
- ត្រូវមានការការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលឲ្យស៊ីជម្រៅនិងសមស្របតាមពេលវេលា គ្រប់អ្នកពាក់ព័ន្ធនូវគោលការណ៍ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនិងការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ការសម្របសម្រួលត្រូវគោរពតាមគោលការណ៍៖សមត្ថភាព ការយល់ដឹង ឆន្ទៈ ការចូលរួម និងទំនាក់ទំនង
- ត្រូវមានរបបប្រជុំជាទៀងទាត់ប្រចាំត្រីមាសឬឆមាសរវាងសមាជិកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈដើម្បីពិនិត្យមើលលើវឌ្ឍនភាពការងារដោយមានការចូលរួមពីដៃគូអភិវឌ្ឍ។

(៣) ដំណោះស្រាយពាក់ព័ន្ធនិងយន្តការប្រព័ន្ធរាយការណ៍ ក្នុងត្រូវផ្តោតទៅលើ៖
- ត្រូវមានយន្តការជាក់លាក់ក្នុងការផ្តល់របាយការណ៍ និងទម្រង់របាយការណ៍ត្រូវមានភាពសាមញ្ញ ងាយស្រួលក្នុងការបំពេញ
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវមានសមត្ថកិច្ច និងទំនាក់ទំនងជាមួយនឹងអង្គភាពជំនាញ ដើម្បីយកទិន្នន័យមកដាក់ក្នុងរបាយការណ៍
- ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពក្នុងការផ្តល់របាយការណ៍វឌ្ឍនភាពការងារជាទៀងទាត់

## ៧. មេរៀនទទួលបានក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីជាតិ

នៅក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនាពេលកន្លងមកនេះ យើងទទួលបាននូវមេរៀន និងបទពិសោធន៍មួយចំនួនក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីជាតិនេះ ក្នុងនោះរួមមាន៖

- ភាពជាម្ចាស់និងបុរេសកម្មចំពោះការងារកែទម្រង់
- ការប្រមូលផ្តុំនិងប្រើប្រាស់ធនធាន ដែលមានស្រាប់
- ការសម្របសម្រួលនិងការគាំទ្រគ្នាទៅវិញទៅមកនៅផ្ទៃក្នុងក្រសួង និងរវាងក្រសួង ស្ថាប័ន
- ការពិគ្រោះយោបល់ដ៏ទូលំទូលាយ

- ការទទួលយកគំនិតផ្តួចផ្តើមថ្មីៗនិងការហ៊ានប្រឈមនឹងហានិភ័យ
- ការដោះស្រាយបញ្ហាផ្អែកលើការយល់ដឹងបញ្ហាជារួម
- ការដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន ត្រូវផ្សារជាមួយនឹងការប៉ាន់ប្រមាណទុកជាស្រេចពីផលវិបាកនាអនាគត
- ការអនុវត្តការងារផ្តើមចេញពីចំណុចសាមញ្ញ ងាយទទួលយក និងការគិតគូរត្រឹមត្រូវពីដើមទី
- ការកំណត់អាទិភាពនៃការងារនិងជំហានត្រូវដើរដោយត្រឹមត្រូវ
- ការអនុវត្តការងារឈរលើទស្សនៈដើម្បីប្រសិទ្ធភាព
- ការជ្រើសរើសនិងប្រើប្រាស់អភិក្រមការងារដោយត្រឹមត្រូវ
- ការថ្លឹងថ្លែងរវាងមហិច្ឆតានិងស្ថានភាពការងារជាក់ស្តែង
- ភាពទន់ភ្លន់និងការប្រមូលផ្តុំការគាំទ្រ
- ការតាមដាននិងត្រួតពិនិត្យជាប្រចាំ។

ទន្ទឹមនឹងមេរៀនបទពិសោធន៍នៃការអនុវត្តដែលយើងទទួលបានកន្លងមក ក៏នៅមានបញ្ហាមួយចំនួនដែលយើងត្រូវយកចិត្តទុកដាក់បន្ថែមលើបញ្ហាមួយចំនួនក្នុងនោះរួមមាន៖

- ការផ្សារភ្ជាប់កំណែទម្រង់រដ្ឋបាលសាធារណៈជាមួយកំណែទម្រង់តាមវិស័យនិងដើម្បីគាំទ្រកំណែទម្រង់តាមវិស័យ
- ការត្រួតពិនិត្យឡើងវិញ និងធ្វើការវាយតម្លៃរួមគ្នារវាងកម្មវិធីកំណែទម្រង់ទាំងបី ដើម្បីកំណត់សកម្មភាពរួមគ្នា និងប្រទាក់ក្រឡាគ្នា
- ជំរុញការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីកំណែទម្រង់៖ គណៈអភិបាល និងក្រុមប្រឹក្សា
- ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងផលវិបាកលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស
- ការរៀបចំឱ្យមានប្រព័ន្ធតាមដាននិងវាយតម្លៃរួមក្នុងរាជរដ្ឋាភិបាលសម្រាប់ការងារកែទម្រង់ទាំងបី និងកម្មវិធីកែទម្រង់តាមវិស័យ ដោយផ្សារភ្ជាប់ជាមួយយន្តការលើកទឹកចិត្ត និងការកែលម្អ
- ការរៀបចំឱ្យមានកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់សកម្មភាពកែទម្រង់ និងការកសាងសមត្ថភាពមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន
- ការពង្រឹងភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ និងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពលើការងារកែទម្រង់។

## ៨. ទិសដៅការងារដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៧

នៅក្នុងការកំណត់ទិសដៅការងារអាទិភាពជំហានបន្ទាប់ គឺផ្តោតទៅលើសមាសធាតុសំខាន់៣ រួមមាន៖ ការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស។

### ៨.១. ការកែលម្អគុណភាពសេវាសាធារណៈ

ការកែលម្អគុណភាពសេវាសាធារណៈ ដែលត្រូវអនុវត្តបន្តនៅឆ្នាំ២០១៧ គឺសង្កត់ធ្ងន់លើសកម្មភាពការងារជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- រៀបចំបង្កើតមជ្ឈមណ្ឌលទូរស័ព្ទព័ត៌មានសេវាសាធារណៈ (Call Centre)

- រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្ដីពីសេវាសាធារណៈ
- រៀបចំ និងដាក់ឱ្យអនុវត្តច្រកទ្វារអេឡិកត្រូនិចផ្ដល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)
- ត្រួតពិនិត្យនិងកែលម្អនីតិវិធី និងយន្តការក្នុងការផ្ដល់សេវាសាធារណៈរបស់ក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ
- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាសាធារណៈ ដោយមានការឯកភាពគ្នារវាងក្រសួងមុខងារសាធារណៈ និងក្រសួងសាមី(មួយក្រសួងម្ដង)
- រៀបចំ និងដាក់ឲ្យដំណើរការច្រកចេញចូលតែមួយនៅក្រសួងមុខងារសាធារណៈ
- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃស្ថាប័នរដ្ឋ និងការផ្ដល់ពានរង្វាន់ និងប្រាក់រង្វាន់ដល់ក្រសួងស្ថាប័នសាធារណៈដែលមានស្នាដៃល្អ។

## ៨.២. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

នៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ដែលត្រូវអនុវត្តបន្តនៅឆ្នាំ២០១៧ គឺសង្កត់ធ្ងន់លើសកម្មភាពការងារជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- រៀបចំការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈក្នុងរចនាសម្ព័ន្ធគ្រប់គ្រង
- ត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា
- រៀបចំពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំអភិវឌ្ឍនិងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្ដុះបណ្ដាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្ដុះបណ្ដាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រីកវិសាលភាពនៃការបណ្ដុះបណ្ដាលមន្ត្រីជាន់ខ្ពស់ មធ្យម និងមន្ត្រីក្របខណ្ឌថ្មី
- ជំរុញការអនុវត្តព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំរុញការអនុវត្តសារាចរណែនាំ ស្ដីពីបែបបទនីតិវិធី អនុវត្តព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំព្រះរាជក្រឹត្យស្ដីពីគោលការណ៍រួមនៃការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- រៀបចំអង្គមន្ត្រីរាជការស៊ីវិល និងមុខតំណែងវិជ្ជាជីវៈ
- រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្ត
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និងប្រវត្តិសមត្ថភាពការងារ
- រៀបចំព្រះរាជក្រឹត្យក្រមសីលធម៌មន្ត្រីរាជការស៊ីវិល។

## ៨.៣. ការកែទម្រង់ប្រព័ន្ធបៀវត្ស

នៅក្នុងការកែទម្រង់ប្រព័ន្ធបៀវត្ស ដែលត្រូវអនុវត្តបន្តនៅឆ្នាំ២០១៧ គឺសង្កត់ធ្ងន់លើសកម្មភាពការងារជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- រៀបចំជំទ្បើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារនិងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល
- សិក្សា និងរៀបចំគោលនយោបាយបៀវត្ស ២០១៨-២០២៣
- រៀបចំបង្កើតកម្មវិធី និងដាក់ឲ្យដំណើរការការកាត់ពន្ធបៀវត្សរបស់ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នឯករាជ្យ។

## ៨.៤. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

- រៀបចំត្រួតពិនិត្យមើលវឌ្ឍភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ
- ចុះតាមដាន និងត្រួតពិនិត្យលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ឱ្យអនុវត្តមានដូចជា៖ (១)កំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (២)ការរៀបចំការពិពណ៌នាមុខតំណែង (៣)ការពង្រឹងវត្តមានមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ជាដើម
- ចុះតាមដាន និងត្រួតពិនិត្យចំនួនមន្ត្រីរាជការក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# ៩. សេចក្តីសន្និដ្ឋាន

នៅក្នុងរយៈពេលមួយឆ្នាំនេះ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ទទួលបានលទ្ធផលវិជ្ជមានមួយចំនួន ក្នុងនោះរួមមានការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងក្រសួងស្ថាប័នថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា។ ទន្ទឹមនឹងវឌ្ឍនភាពការងារជាវិជ្ជមាននេះ ក៏ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន និងសកម្មភាពការងារជាច្រើនដែលទាមទារឱ្យមានការចូលរួមសហការ ដោះស្រាយ និងអនុវត្តការងារទាំងនេះរួមគ្នា ដើម្បីគោលដៅរួមក្នុងការបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ ការជំរុញ និងការតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាសាធារណៈ គឺត្រូវតែបន្តអនុវត្តឱ្យបានជាប់ជាប្រចាំ។